ឆ្នាំ ទី ៨ លេខ ១១ សប្តាហ៍ទី ២ ថ្ងៃ ទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៨ រាជកិច្ច ទំព័រ ១១២០

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ០១ អនក្រ**

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំបទដ្ឋានគតិយុត្ត និងនីតិវិធីស្តីពីការប្រើប្រាស់ដីធ្លី នៅខេត្ត ក្រុង និងទីប្រជុំជន នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និង សំណង់
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងរៀបចំបទដ្ឋានគតិយុត្តនិងនីតិវិធីស្តីពីការប្រើប្រាស់ដីធ្លី នៅខេត្ត ក្រុង និងទីប្រជុំជន នៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១. ឯកឧត្តម អ៊ឹម ឈុនលឹម | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាប្រធាន |
| ២. ឯកឧត្តម ញ៉ឹ សុខា | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| ៣. ឯកឧត្តម នុត សាអ៊ាន | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាអនុប្រធាន |
| ៤. ឯកឧត្តម តៀង សុគំណ្ឌ | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាសមាជិក |
| ៥. ឯកឧត្តម កែច ខេមរ៉ា | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាសមាជិក |
| ៦. ឯកឧត្តម អ៊ូ ច៊ុនឡុង | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៧. ឯកឧត្តម លឹម សុគុន | រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ៨. ឯកឧត្តម យិន គឹមស៊ាន | រដ្ឋលេខាធិការ ក្រសួងបរិស្ថាន | ជាសមាជិក |
| ៩. ឯកឧត្តម លី ប្រុស | រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ១០. ឯកឧត្តម ត្រាំ អ៊ីវតឹក | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| ១១. ឯកឧត្តម សំ សារិត | រដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | ជាសមាជិក |

១២. ឯកឧត្តម ហ៊ុល លីម — រដ្ឋលេខាធិការ ក្រសួងផែនការ — ជាសមាជិក

១៣. ឯកឧត្តម ឌុច ចនធីនូ — អគ្គនាយក នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — ជាសមាជិកអចិន្ត្រៃយ៍

១៤. លោក គីកវៃត សំរេច — ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី — ជាសមាជិក។

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ចរៀបចំបទដ្ឋានគតិយុត្ត និងនីតិវិធីស្តីពីការប្រើប្រាស់ដីធ្លី នៅខេត្ត ក្រុង និងទីប្រជុំជន នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

**ប្រការ ៣ :** គណៈកម្មការនេះមានលេខាធិការដ្ឋានជាជំនួយការមួយ មានទីតាំងក្នុងទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលមានសមាសភាពដូចខាងក្រោម :

១. ឯកឧត្តម ឌុច ចនធីនូ — អគ្គនាយក នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — ជាប្រធាន

២. លោក ប៉េងហុង សុជាតិខេមរ៉ូ — អគ្គនាយករង នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — ជាសមាជិក

៣. លោក ហេង ម៉ុណ្ណារ៉ាត់ — អគ្គនាយករង នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — ជាសមាជិក

៤. លោកស្រី សួស សុផល — អគ្គនាយករង នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — ជាសមាជិក

៥. លោក ម៉ែន សុផល — ប្រធាននាយកដ្ឋាននគរូបនីយកម្មនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — ជាសមាជិក

៦. លោក ទ្រាត់ អន្តារ៉ា — ប្រធាននាយកដ្ឋានស្រាវជ្រាវ និងបទប្បញ្ញត្តិ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — ជាសមាជិក។

លេខាធិការដ្ឋាននេះមានភារកិច្ចដូចខាងក្រោម :

- ស្រាវជ្រាវច្បាប់ និងឯកសារនានា ដើម្បីគាំទ្រផ្នែកបច្ចេកទេសក្នុងការរៀបចំបទដ្ឋានគតិយុត្ត និងនីតិវិធីស្តីពីការប្រើប្រាស់ដីធ្លី នៅខេត្ត ក្រុង និងទីប្រជុំជន នៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំឯកសារ និងរបាយការណ៍បច្ចេកទេសឆ្លងកិច្ចប្រជុំគណៈកម្មការអន្តរក្រសួង
- រៀបចំសេចក្តីព្រាងរបាយការណ៍ឆ្លងកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងដើម្បីពិនិត្យ និងសម្រេច ។

លេខាធិការដ្ឋាននេះ អាចប្រើប្រាស់មន្ត្រី នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម និង អង្គភាពផ្សេងទៀត នៃក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និង សំណង់ ឱ្យជួយការងារតាមការចាំបាច់ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ និងប្រការ ៣ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*